00652394

F14/5

# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០១/១៨-០៧-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី16 ខែមីនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: សាធារណៈ / Public

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្ដីសង្ខេបរបស់សហព្រះរាជអាជ្ញា នៅលើសារណាបណ្ដឹងសាទុក្ខច្បាប់កែតម្រូវ ជាភាសាអង់គ្លេស ធ្វើឡើងដោយសហមេធាវីការពារក្ដី កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច" ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី:** |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះតុលាការកំពូល: | លោក គង់ ពិសី |
| លោកស្រី ជា លាង | ចៅក្រម គង់ ស្រ៊ីម, ប្រធាន | លោក ហុង គឹមសួន |
| លោក Andrew CAYLEY | ចៅក្រម Motoo NOGUCHI | លោក យុង ផានិត |
| | ចៅក្រម សោម សិរីវឌ្ឍ | លោក គឹម ម៉េងឃី |
| | ចៅក្រម A. KLONOWIECKA-MILART | កញ្ញា ម៉ុច សុវណ្ណារី |
| | ចៅក្រម ស៊ិន រិទ្ធ | កញ្ញា SILKE Studzinsky |
| | ចៅក្រម C. N. JAYASINGHE | លោកស្រី Martine JACQUIN |
| | | លោក Philippe CANONNE |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 16 / 03 / 2011
ម៉ោង (Time/Heure): 15:55
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

F1/5

*សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក*

| | |
|---|---|
| ចៅក្រម យ៉ា ណារិន | លោកស្រី ទី ស្រ៊ុនណា |
| | លោក Pierre-Olivier SUR |
| **មេធាវីជនជាប់ចោទ:** | លោក Alain WERNER |
| **កាំង ហ្គេកអ៊ាវ *ហៅ* ឌុច:** | លោក Brianne McGONIGLE |
| | លោកស្រី Annie DELAHAIE |
| លោក ការ សាវុត្ថ | លោកស្រី Elizabeth RABESANDRATANA |
| លោក កង ឫទ្ធារី | លោក Karim KHAN |
| | លោកស្រី Fabienne TRUSSES-NAPROUS |

## ១. សេចក្តីផ្តើម

១. នៅថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ២០១០ ជនជាប់ចោទ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ("ជនជាប់ចោទ") បានដាក់សារណាបណ្តឹងសាទុក្ខ ធ្វើឡើងដោយសហមេធាវីការពារក្តី កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("បណ្តឹងសាទុក្ខដើម")[1]។ សហព្រះរាជអាជ្ញា បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខនេះ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ ("ចម្លើយតបរបស់ កសព")[2]។ សហព្រះរាជអាជ្ញាបានទទួលការជូនដំណឹងនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១០ អំពីច្បាប់បកប្រែភាសាអង់គ្លេសនៃបណ្តឹងសាទុក្ខដើមដែលបានកែតម្រូវ ("បណ្តឹងសាទុក្ខដែលបានកែតម្រូវ") ដែលមានការកែតម្រូវជាសារវ័ន្តត្រូវបានគេធ្វើឡើង[3]។

២. គេហាក់ដូចជាគ្មានពេលវេលាកំណត់ណាមួយសម្រាប់ការដាក់ការកែតម្រូវនៃច្បាប់បកប្រែទេ ដែលការណ៍នេះ ត្រូវតែបានអនុម័តដោយអង្គភាពបកប្រែ[4]។ យ៉ាងណាមិញ កសព កត់សំគាល់ឃើញថា សារណាបណ្តឹងសាទុក្ខដែលបានកែតម្រូវរបស់ដើមបណ្តឹងសាទុក្ខ ជាភាសាអង់គ្លេស ត្រូវបានដាក់ជាងពីរខែក្រោយពីការដាក់លើកដំបូង និងជាងមួយខែក្រោយពី កសព បានដាក់សេចក្តីសន្និដ្ឋានតបរបស់ខ្លួន ។ គ្មានការជូនដំណឹងដល់ កសព ទេ ទាក់ទិននឹងការបកប្រែឡើងវិញនេះ។

៣. សហព្រះរាជអាជ្ញា គោរពចំពោះភាពចាំបាច់នៃការដាក់ឯកសារបកប្រែដែលត្រឹមត្រូវ លើគ្រប់ភាសាទាំងអស់ និងតម្រូវការក្នុងការស្នើសុំកែតម្រូវលើឯកសារដែលដាក់បើសិនជាការបកប្រែមិនត្រឹមត្រូវ។ ប៉ុន្តែ ក្នុងកាលៈទេសៈនេះ ជាជាងការកែសម្រួលទៅលើការភាន់ច្រឡំខាងផ្នែកបកប្រែ ការផ្លាស់ប្តូរខ្លះទៅលើបណ្តឹងសាទុក្ខដែលបានកែតម្រូវ ហាក់ដូចជាការកែបន្ថែមបន្ថយផ្នែកច្បាប់ ឱ្យស្របទៅតាមចម្លើយតបរបស់សហព្រះរាជអាជ្ញា។ ការសន្និដ្ឋាននេះ ត្រូវបានពង្រឹងតាមការពិនិត្យដោយអ្នកច្បាប់

[1] សារណារបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក, មេធាវីការពារក្តី, ១៨ វិច្ឆិកា ២០១០, F14 ("បណ្តឹងសាទុក្ខដើម") ។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ប្រឆាំងនឹងសាលក្រមរបស់អង្គជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក, ការិយាល័យសហព្រះរាជអាជ្ញា, ២០ ធ្នូ ២០១០, F14/4 ("ចម្លើយតបរបស់ កសព") ។

[3] សារណារបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក, មេធាវីការពារក្តី, ១៨ វិច្ឆិកា ២០១០, (សំណើសុំកែតម្រូវ ដាក់ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១), F14/Corr-2 ("បណ្តឹងសាទុក្ខដែលបានកែតម្រូវ") ។

[4] ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៥, ១៧ កញ្ញា ២០១០, មាត្រា៣.១៧។

ជនជាតិខ្មែរនៅ កសព ដែលចេះភាសាអង់គ្លេសដែរ បង្ហាញឱ្យឃើញថា សារណាដើមជាភាសាខ្មែរ ដែលបកប្រែមានន័យដូចគ្នាច្រើនទៅនឹងឯកសារដើមជាភាសាអង់គ្លេសនៅត្រង់ចំណុចខ្លះ។

៤. ជាការបន្ថែម ការដកស្រង់ជាច្រើនពីបណ្តឹងសាទុក្ខដើមដែលបានលើកយោងនៅក្នុងចម្លើយតបរបស់ កសព ឥឡូវនេះបានផ្លាស់ប្តូរ ធ្វើឱ្យចម្លើយតបរបស់សហព្រះរាជអាជ្ញាមើលទៅដូចជាមិនច្បាស់លាស់ និងគ្មានខ្លឹមសារត្រង់ផ្នែកខ្លះ។

៥. ដើម្បីបញ្ជាក់បំភ្លឺដល់អង្គជំនុំជម្រះតុលាការកំពូល សហព្រះរាជអាជ្ញាបានធ្វើការចង្អុលបង្ហាញនិងចម្លង ផ្នែកទាំងនោះពីច្បាប់បកប្រែភាសាអង់គ្លេសនៃបណ្តឹងសាទុក្ខដើម និងបណ្តឹងសាទុក្ខដែលបានកែតម្រូវ ទាក់ទិននឹង៖១) ការផ្លាស់ប្តូរជាក់ស្តែងទៅលើបណ្តឹងសាទុក្ខដែលបានកែតម្រូវឱ្យស្របទៅនឹងចម្លើយ តបរបស់សហព្រះរាជអាជ្ញា និង ២) ការដកស្រង់ចេញពីបណ្តឹងសាទុក្ខដើម ដែលបានលើកយោងក្នុង ចម្លើយតបរបស់ កសព។ ឥឡូវនេះបានផ្លាស់ប្តូរដោយកែតម្រូវនៅក្នុងបណ្តឹងសាទុក្ខដែលបានកែតម្រូវ

## ២. ការផ្លាស់ប្តូរដើម្បីឲ្យចម្លើយតប នៅក្នុងបណ្តឹងសាទុក្ខដែលបានកែតម្រូវ

៦. សហព្រះរាជអាជ្ញាអះអាងថា ជនជាប់ចោទបានជ្រើសរើសមិនជំទាស់អំពីបញ្ហាយុត្តាធិការ "ដោយដឹង ខ្លួន និងគិតទុកជាមុន"[5] ។ សម្រាប់ជាការលើកយោងដើម្បីគាំទ្រ ក្នុងចម្លើយតបរបស់ កសព បានដក ស្រង់បណ្តឹងសាទុក្ខដើម ដែលបាននិយាយថា "មេធាវីការពារក្តី មិនជំទាស់នឹងសហព្រះរាជអាជ្ញាទេ [ទាក់ទិននឹងយុត្តាធិការ] កាលពីដំបូង[6]។ នៅក្នុងបណ្តឹងសាទុក្ខដែលបានកែតម្រូវ ឃ្លាមួយនេះត្រូវបាន ដកចេញ ហើយជំនួសមកវិញ និយាយថា មេធាវីការពារក្តីមិនត្រូវបានគេផ្តល់ឱកាសឱ្យជំទាស់អំពី យុត្តាធិការរបស់តុលាការទៅលើជនជាប់ចោទឡើយ ។

ក. <u>បណ្តឹងសាទុក្ខដើម, កថាខណ្ឌ៩៤:</u> "...មេធាវីការពារក្តីមិនជំទាស់ទៅនឹងសហព្រះរាជអាជ្ញា នៅគ្រាដំបូង..." ។

ខ. <u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌ៩៥:</u> "...មេធាវីការពារក្តីមិនត្រូវបានផ្តល់ឱកាស តាំងពីគ្រាដំបូងឱ្យឆ្លើយតបទៅនឹងបទចោទរបស់សហព្រះរាជអាជ្ញាទេ..." ។

[5] ចម្លើយតបរបស់ កសព, កថាខ័ណ្ឌទី១៦ ។

[6] ចម្លើយតបរបស់ កសព, កំណត់សំគាល់ចុងទំព័រលេខ៣៥ ។

៧. សហព្រះរាជអាជ្ញា បានធ្វើការកត់សំគាល់ក្នុងចម្លើយតបរបស់ កសព ថា ជនជាប់ចោទបានកាត់យល់ខុសពីចេតនានៃការខ្វែងយោបល់របស់ចៅក្រមមួយរូបនៃចៅក្រមអង្គសវនាការជំនុំជម្រះៈ "[*] ដើមបណ្តឹងសាទុក្ខអះអាងដោយខុសថា ការខ្វែងយោបល់របស់ចៅក្រម Lavergne "បានសារភាពថាអង្គសវនាការជំនុំជម្រះ ខ្វះយុត្តាធិការទៅលើជនជាប់ចោទ" ។ ផ្ទុយមកវិញ ការខ្វែងយោបល់នេះគឺបានកំហិតត្រឹមតែការពិភាក្សាអំពីចំនួនទោសត្រូវដាក់ទៅលើដើមបណ្តឹងសាទុក្ខប៉ុណ្ណោះ"[7]។ បណ្តឹងសាទុក្ខដែលបានកែតម្រូវ បានធ្វើការកែសម្រួលភាសាដែលបានប្រើនៅក្នុងបណ្តឹងសាទុក្ខដើម ដើម្បីបញ្ជាក់ពីចរិតលក្ខណៈនៃអានុភាពនៃការខ្វែងយោបល់របស់ចៅក្រម Lavergne។

ក. <u>**បណ្តឹងសាទុក្ខដើម, កថាខណ្ឌ៩៦:**</u> "*ភស្តុតាងបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងគ្មានយុត្តាធិការលើបុគ្គល កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈការទទួលយក និងការទទួលស្គាល់ដោយសហចៅក្រមជាតិ និងអន្តរជាតិដោយហេតុថា យ៉ាងហោចណាស់មានចៅក្រមអន្តរជាតិមួយរូប បានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពិតជាគ្មានយុត្តាធិការលើឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច*" ។

ខ. <u>**បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌ៩៦:**</u> "*លើសពីនេះ មតិខ្វែងយោបល់របស់ចៅក្រមអន្តរជាតិ ដែលឆ្លុះបញ្ចាំងពីជំនឿរបស់គាត់ថា អង្គជំនុំជម្រះសាលាដំបូង គ្មានយុត្តាធិការលើកាំង ហ្គេកអ៊ាវ ហៅ ឌុច មានតម្លៃស្មើនឹងភស្តុតាងបញ្ជាក់ថា គ្រប់ចៅក្រមជំនុំជម្រះទាំងអស់ទាំងចៅក្រមជាតិ និងចៅក្រមអន្តរជាតិ បានដឹងនិងទទួលស្គាល់ថា អ.វ.ត.ក មានកង្វះខាតនៃយុត្តាធិការបុគ្គលដើម្បីទទួលយកសំណុំរឿងលេខ០០១*" ។

៨. សហព្រះរាជអាជ្ញា បានកត់សំគាល់ឃើញថា នៅក្នុងឃ្លាជាច្រើន មេធាវីការពារក្តីបានលើកយោងនូវ "សេចក្តីសន្និដ្ឋាន" របស់ខ្លួន ដោយពុំបានបង្ហាញថាតើ សេចក្តីសន្និដ្ឋានទាំងនេះ បានធ្វើដោយរបៀបណា ឬពីពេលណាមកទេៈ "[t] ដើមបណ្តឹងសាទុក្ខយោងដដែលៗពីការខកខានរបស់អង្គសវនាការជំនុំជម្រះដែលមិនបានពិចារណាលើ "សេចក្តីសន្និដ្ឋាន" របស់ខ្លួនស្តីពីយុត្តាធិការបុគ្គល ប៉ុន្តែខកខានមិនបានបញ្ជាក់ពីសេចក្តីសន្និដ្ឋានណាមួយដែលខ្លួនយោង ឬក៏និយាយច្បាស់លាស់ថា សេចក្តីសន្និដ្ឋាននោះត្រូវបានធ្វើឡើងនៅពេលណា ទោះបីទាំងអស់នេះ ជាក់ស្តែងគឺជាអង្គហេតុដ៏សំខាន់ក៏ដោយ"[8]។ ក្នុងបណ្តឹងសាទុក្ខដែលបានកែតម្រូវ នៅត្រង់កន្លែងខ្លះ គឺបានបន្ថែមការបញ្ជាក់បំភ្លឺបន្ថែមទៀតទាក់ទិននឹង "សេចក្តីសន្និដ្ឋាន"ទាំងនេះ ហើយនៅកន្លែងផ្សេងទៀតប្រើពាក្យ "អញ្ញត្រកម្ម" ឬ "អំណះអំណាង" ជាជាងការប្រើពាក្យ "សេចក្តីសន្និដ្ឋាន" ។

---

[7] ចម្លើយតបរបស់ កសព, កថាខ័ណ្ឌទី៨ ។

[8] ចម្លើយតបរបស់ កសព, កថាខ័ណ្ឌទី៨ ។

ក. <u>បណ្តឹងសាទុក្ខដើម, កថាខណ្ឌ៥ (សង្កត់ន័យត្រង់អក្សរទ្រេត):</u> "ជាលទ្ធផល សហមេធាវីជនជាប់ចោទបានព្យាយាមលើកឡើងម្តងទៀត នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន និង ស្នើសុំឱ្យចៅក្រមពិនិត្យឡើងវិញលើភស្តុតាងរបស់មេធាវីការពារក្តី ដែលអះអាងបញ្ជាក់ថា បទប្បញ្ញត្តិនៃមាត្រា១ នៃកិច្ចព្រមព្រៀង និងមាត្រា១ និងមាត្រា២(ថ្មី)នៃច្បាប់ អ.វ.ត.ក មិនអនុវត្តចំពោះជនជាប់ចោទ" ទេ ។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌ៥ (សង្កត់ន័យត្រង់អក្សរទ្រេត):</u> "ដោយសារមូលហេតុទាំងនេះ សហមេធាវី កាំង ហ្កេកអ៊ាវ ហៅ ឌុច បានព្យាយាមម្តងទៀតដើម្បីលើកពីបញ្ហាយុត្តាធិការរបស់ អ.វ.ត.ក នៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួន ដោយស្នើឱ្យចៅក្រមពិនិត្យឡើងវិញលើភស្តុតាងដែលបញ្ជាក់ថា មាត្រា១នៃកិច្ចព្រមព្រៀង និងមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ អ.វ.ត.ក មិនអនុវត្តចំពោះ កាំង ហ្កេកអ៊ាវ" ។

ខ. <u>បណ្តឹងសាទុក្ខដើម, កថាខណ្ឌ៦៦ (សង្កត់ន័យត្រង់អក្សរទ្រេត):</u> "អង្គជំនុំជម្រះបានខកខានមិនបានមើលវិធាន៨៧ នៃវិធានផ្ទៃក្នុង សម្រាប់ អ.វ.ត.ក និង សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ដោយផ្អែកតែទៅលើវិធាន៨៩ប៉ុណ្ណោះ ។ ការច្រានចោលនូវ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ដែលបានពឹងផ្អែកលើភស្តុតាងទាំងស្រុងដែលបានដាក់ដោយសហព្រះរាជអាជ្ញានៅអង្គជំនុំជម្រះ ហើយទាញចេញពីវិធាន៨៩ ទាំងស្រុង គឺបំពានទៅលើវិធាន៨៧ ដែលនាំធ្វើឱ្យភស្តុតាងដោះបន្ទុកមិនត្រូវបានគេយកមកពិនិត្យទាំងស្រុង ក្នុងការធ្វើឱ្យប្រាកដថា អ.វ.ត.ក ពិតជាគ្មានយុត្តាធិការលើជនជាប់ចោទមែនដែរឬទេ តាមការសន្និដ្ឋាន របស់មេធាវីការពារក្តី" ។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌ៦៦ (សង្កត់ន័យត្រង់អក្សរទ្រេត):</u> "តាមការច្រានចោលនូវ *សេចក្តីសន្និដ្ឋាននានា នៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយរបស់មេធាវីការពារក្តី* អង្គជំនុំជម្រះសាលាដំបូងបានពិចារណាតែទៅលើវិធាន៨៩ នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ ដោយមិនបានពិចារណាទៅលើវិធាន៨៧ទេ។ ការច្រានចោលដែលផ្អែកទៅលើតែភស្តុតាងដែលបានលើកសំអាងនៅចំពោះមុខអង្គជំនុំជម្រះ និងវិធាន៨៩ មានតម្លៃស្មើនឹងការរំលោភវិធាន៨៧ ដែលក្នុងនោះគ្មានភស្តុតាងដោះបន្ទុកត្រូវបានគេវាយតម្លៃដើម្បីផ្ទៀងផ្ទាត់ថា តើ អ.វ.ត.ក ពិតជាគ្មានយុត្តាធិការលើ កាំង ហ្កេកអ៊ាវ មែនឬទេ *តាមការសន្និដ្ឋានមេធាវីការពារក្តី នៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួន*" ។

គ. <u>បណ្តឹងសាទុក្ខដើម, កថាខណ្ឌ៧០ (សង្កត់ន័យត្រង់អក្សរទ្រេត):</u> "មាត្រា២៩០(៦) នេះ ក៏អាចត្រូវបានគេមើលឃើញដូចគ្នាដែរដែលអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក អាចយកមកប្រើ

បានបើសិនជាខ្លួនបានពិនិត្យមើលភស្តុតាងតាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ហើយយល់ស្របថាពិតជាគ្មានយុត្តាធិការលើបុគ្គលជនជាប់ចោទប្រាកដមែន ។ ការលើកយកវិធាន ៨៩ នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក មកទាត់ចោល *សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី* វាបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះក៏យល់ឃើញស្របដូចការលើកឡើងរបស់មេធាវីការពារក្តីថា ជនជាប់ចោទមិនស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ តែគ្រាន់តែជាការលើកឡើងរបស់មេធាវីយឺតពេលប៉ុណ្ណោះ ហេតុនេះអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ត្រូវតែប្រកាសថាពុំមានសមត្ថកិច្ចដោយសាលក្រមដូចមាត្រា២៩០(៦) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមានចែងស្រាប់ ។ ហេតុនេះ ការលើកឡើងដោយមេធាវីការពារក្តីនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនជូនអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ថា ជនជាប់ចោទមិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក មិនអាចត្រូវបានច្រានចោលដោយសំអាងថា លើកឡើងយឺតពេលនោះទេ ព្រោះសេចក្តីសំអាងទាំងអស់ដែលលើកឡើងដោយមេធាវីការពារក្តី គឺទាញចេញពីវិធាន៨៧(១) ទាំងស្រុង...” ។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌ៦៨ (សង្កត់ន័យត្រង់អក្សរទ្រេត):</u> “មាត្រា ២៩០(៦) នេះ ក៏អាចឱ្យគេបកស្រាយតាមរបៀបដូច្នេះដែរ ហើយការណ៍នេះមានន័យថា - បើសិនអង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលភស្តុតាង *ដែលបានដាក់ជូនដោយមេធាវីការពារក្តីនៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួន* នោះអង្គជំនុំជម្រះសាលាដំបូង នឹងទទួលស្គាល់ថា ខ្លួនពិតជាគ្មានយុត្តាធិការលើ កាំង ហ្គេកអ៊ាវ ហៅ ឌុច មែន ។ ដោយការផ្អែកតែទៅលើវិធាន៨៩ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះហាក់ដូចជាចង់បង្កប់ន័យថា ខ្លួនក៏យល់ឃើញស្របដូចមេធាវីការពារក្តីដែរថា កាំង ហ្គេកអ៊ាវ មិនស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ ។ ការពិតនេះហើយដែលអង្គជំនុំជម្រះសាលាដំបូងគេចវេសពីបញ្ហានេះដោយអះអាងថា ញត្តិចាត់របៀប របស់មេធាវីយឺតពេល ។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.កគួរតែបានអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា២៩០(៦) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន និងច្រានចោលយុត្តាធិការ ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនអាចបដិសេធសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីដែលថា កាំង ហ្គេកអ៊ាវ មិនស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ព្រោះតែយឺតពេលនោះទេ ជាពិសេសដោយគិតគូរទៅលើសេចក្តីសំអាងទាំងអស់របស់មេធាវីការពារក្តី ដែលទាញចេញពីវិធាន៨៧(១)ទាំងស្រុង” ។

ឃ. <u>បណ្តឹងសាទុក្ខដើម, កថាខណ្ឌ៧១ (សង្កត់ន័យត្រង់អក្សរទ្រេត):</u> “អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ខកខានមិនបានពិនិត្យមើលសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ គឺបានបំពានវិធាន ៩២ និង វិធាន ៩៣ នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក ទាំងស្រុង...” ។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខ័ណ្ឌ៧១ (សង្កត់ន័យត្រង់អក្សរទ្រេត):</u> "ការច្រានចោល*អំណះអំណាង* របស់មេធាវីការពារក្តី គឺអង្គជំនុំជម្រះសាលាដំបូងបានបំពានទាំងស្រុងទៅលើវិធាន ៩២ និង វិធាន ៩៣ នៃវិធានផ្ទៃក្នុង..."។

ង. <u>បណ្តឹងសាទុក្ខដើម, កថាខណ្ឌ៧១:</u> "ការទាត់ចោលភស្តុតាងចង្អុលបង្ហាញពីបញ្ហាយុត្តាធិការរបស់តុលាការ ដោយការលើកឡើងថា សេចក្តីសន្និដ្ឋានបានធ្វើឡើងយឺតពេល មិនអាចទទួលយកបានឡើយនៅតាមបណ្តាប្រព័ន្ធតុលាការនៅអារ្យប្រទេសមួយចំនួន"។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌ៧១:</u> "អាស្រ័យហេតុនេះ យោងតាមប្រព័ន្ធច្បាប់នៅបណ្តាអារ្យប្រទេសមួយចំនួនធំ គឺមិនទទួលយកបានឡើយចំពោះការច្រានចោលជាមុននូវភស្តុតាងទាំងឡាយទាក់ទងនឹងយុត្តាធិការដោយសំអាងថា បានដាក់ក្រោយពេលនោះ"។

ច. <u>បណ្តឹងសាទុក្ខដើម, កថាខណ្ឌ៩៤ (សង្កត់ន័យត្រង់អក្សរទ្រេត):</u> "... តុលាការបានពិចារណាថា ខ្លួនមានយុត្តាធិការលើរូបគាត់ និងបានច្រានចោល *សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី* ថាជាអញ្ញត្រកម្មបឋមលើកឡើងយឺតពេល"។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌ៩៤ (សង្កត់ន័យត្រង់អក្សរទ្រេត):</u> "... ហេតុដូច្នេះហើយបានជាអង្គជំនុំជម្រះសាលាដំបូង បានជម្រះក្តី កាំង ហ្គេកអ៊ាវ ដោយភាន់ច្រឡំថាគាត់ស្ថិតក្រោមយុត្តាធិការរបស់ខ្លួន និងថែមទាំងបានច្រានចោល *អញ្ញត្រកម្មរបស់មេធាវីការពារក្តី* ថាជាអញ្ញត្រកម្មលើកឡើងយឺតពេលទៅវិញ"។

## ៣. ការដកស្រង់ពីបណ្តឹងសាទុក្ខដើម ដែលបានលើកយោងនៅក្នុងចម្លើយតបរបស់ កសព ត្រូវបានផ្លាស់ប្តូរនៅក្នុងបណ្តឹងសាទុក្ខដែលបានកែតម្រូវ

៩. សហព្រះរាជអាជ្ញា មានបំណងទប់ស្កាត់ការបាត់បង់ផលប្រយោជន៍ណាមួយមកលើខ្លួនដោយហេតុថាចម្លើយតបរបស់ កសព បានលើកយោងចេញពីបណ្តឹងសាទុក្ខដើម ហើយភាគច្រើនភាសានៃការលើយោងនេះ ពេលនេះត្រូវបានផ្លាស់ប្តូរ ទោះបីខ្លឹមសារហាក់ដូចជាស្រដៀងគ្នាជាទូទៅក៏ដោយ ។ ដើម្បីជាប្រយោជន៍របស់អង្គជំនុំជម្រះតុលាការកំពូល សហព្រះរាជអាជ្ញាសូមផ្តល់ជូននូវសេចក្តីយោងដែលដូចបានលើកនៅក្នុងចម្លើយតបរបស់ខ្លួនដែលបានដកស្រង់ចេញពីបណ្តឹងសាទុក្ខដើម និងសេចក្តីយោងដែលពេលនេះបានផ្លាស់ប្តូរនៅក្នុងបណ្តឹងសាទុក្ខដែលបានកែតម្រូវ ។

ក. ចម្លើយតបរបស់ កសព, កថាខណ្ឌទី៣: "គាត់បានអះអាងថា អវតក ខ្វះយុត្តាធិការបុគ្គលទៅលើរូបគាត់ ហើយគាត់មិនយល់ព្រមទៅនឹងបទដ្ឋានដែលតម្រូវឱ្យមាននោះទេ ពីព្រោះ "គាត់មិនត្រូវបានចាត់ថ្នាក់នៅក្នុងរចនាសម្ព័ន្ធដឹកនាំជាន់ខ្ពស់ និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃកម្ពុជាប្រជាធិបតេយ្យទេ""។

បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី២២: "...គាត់ពុំមែនជាមេដឹកនាំជាន់ខ្ពស់ម្នាក់នៃកម្ពុជាប្រជាធិបតេយ្យទេ ហើយក៏ពុំមែននៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្រោមរបបនេះដែរ"។

ខ. ចម្លើយតបរបស់ កសព, កថាខណ្ឌទី៣: "ដើមបណ្តឹងសាទុក្ខបានធ្វើសេចក្តីសន្និដ្ឋានចុងក្រោយនៅក្នុងសារណារបស់ខ្លួន ដោយទទូចអះអាងថា ដំណើរការនីតិវិធីនៃសំណុំរឿងលេខ ០០១ គួរត្រូវបានចាត់ទុកថាជា "ការជំនុំជម្រះភាន់ច្រឡំ", ការឃុំខ្លួនរបស់គាត់ត្រូវបានចាត់ទុកថាជា "កិច្ចរក្សាការពារសាក្សីមានសក្តានុពល" ហើយថាគាត់ត្រូវតែបានដោះលែង" ។

បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី១០០: "ដំណើរការនីតិវិធីក្នុងសំណុំរឿងលេខ០០១ "ត្រូវតែបានចាត់ទុកថាជាលទ្ធផលនៃការភាន់ច្រឡំមួយដោយអង្គជំនុំជម្រះ" និង [t]"ការឃុំខ្លួន កាំង ហ្គេកអ៊ាវ ចាប់ពីថ្ងៃចាប់ខ្លួនគាត់រហូតដល់បច្ចុប្បន្នត្រូវចាត់ទុកថាជាទម្រង់មួយនៃការការពារ" ។

គ. ចម្លើយតបរបស់ កសព, កំណត់សំគាល់ជើងទំព័រលេខ១៣: "*សូមអាន ជាឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី កថាខណ្ឌទី៤-៦ (ដែលលើកឡើងជាទូទៅដោយមិនមានការយោង ឬលើកសំអាងជាក់លាក់, ដល់ "ភស្តុតាងគាំទ្រ"...)"។

បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៤: "... ភស្តុតាងក្នុងការគាំទ្រ..." ។

ឃ. ចម្លើយតបរបស់ កសព, កំណត់សំគាល់ជើងទំព័រលេខ១៣: "*សូមអាន ជាឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី... កថាខណ្ឌទី២១ (បានតវ៉ាជំទាស់ថាយុត្តាធិការបុគ្គល គឺផ្អែកជាសំខាន់ទៅលើមូលដ្ឋាននៃបទដ្ឋានរដ្ឋបាលរបស់ជាតិដោយពុំបានផ្តល់សេចក្តីយោងទៅលើបទដ្ឋានទាំងនោះឡើយ) ..." ។

បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី២១: "...បទដ្ឋាននៃច្បាប់រដ្ឋបាល..." ។

ង. <u>ចម្លើយតបរបស់ កសព, កំណត់សំគាល់ជើងទំព័រលេខ១៣:</u> "*សូមអាន ជាឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី... កថាខណ្ឌទី២២ (លើកឡើងជាទូទៅ សំដៅលើ "បទដ្ឋានគតិយុត្តិសំខាន់ៗនានារបស់ជាតិ" ដែលបញ្ជាក់ថា ដើមបណ្តឹងសាទុក្ខមិន ត្រូវបានគេចាត់ចូលនៅក្នុងរចនាសម្ព័ន្ធនៃ "មេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់ បំផុត" ដោយមិនបានយោងដោយត្រឹមត្រូវទៅលើបទដ្ឋានទាំងនោះឡើយ) ..." ។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី២២:</u> "...មានឯកសារមួយចំនួនធំពីរដ្ឋ អំណាចជំនាន់នោះ ដែលរៀបរាប់ពីតួនាទី និងមុខតំណែងរបស់គាត់តាមឋានានុក្រម ហើយបង្ហាញថាគាត់ពុំមែនជាមេដឹកនាំជាន់ខ្ពស់ម្នាក់នៃកម្ពុជាប្រជាធិបតេយ្យទេ ហើយក៏ពុំមែននៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែល បានប្រព្រឹត្តក្រោមរបបនេះដែរ" ។

ច. <u>ចម្លើយតបរបស់ កសព, កំណត់សំគាល់ជើងទំព័រលេខ១៣:</u> "*សូមអាន ជាឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី... កថាខណ្ឌទី២៥ (ដែលលើកឡើងជា ទូទៅសំដៅទៅលើ"ទ្រឹស្តីនៃច្បាប់មួយដែលកំណត់និយមន័យអំពីអ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែលមិនបានចែងច្បាស់លាស់ ដែលតាមទ្រឹស្តីនោះគឺឱ្យនិយមន័យជននោះដោយពិនិត្យមើល ទៅលើអំណាចឆន្ទៈរបស់ពួកគេនៅក្នុងឋានានុក្រម និងទៅលើឆន្ទៈក្នុងការសម្រេចជ្រើសរើស របស់ពួកគេ ដោយធ្វើការប្រៀបធៀបទៅនឹងលេខាដទៃៗទៀតនៃពន្ធនាគារ)" ។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី២៥:</u> "តាមទស្សនៈច្បាប់ ដើម្បីធ្វើការ កំណត់រកថាតើបុគ្គលណាមួយត្រូវទៅនឹងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះ វាចាំបាច់ត្រូវកំណត់រកពីអំណាចនានាដែលបុគ្គលនោះមាន ដោយមានមូលដ្ឋាននៅ លើតំណែងតាមឋានានុក្រម" ។

ឆ. <u>ចម្លើយតបរបស់ កសព, លេខយោងជើង ទំព័រទី១៤:</u> "*សូមអាន ឧទាហរណ៍ដូចជា* សារណា បណ្តឹងសាទុក្ខ...កថាខណ្ឌទី២៣, ទី២៥ (ដែលពោលអះអាងដោយងងឹតងងល់ថា ព្រោះនៅ ពន្ធនាគារដទៃទៀត ត្រូវបានគេអះអាងឱ្យដឹងថា មានជនរងគ្រោះច្រើនជាងលើសពីមន្ទីរស-២១ទៅទៀត "នេះគឺជាការបញ្ជាក់យ៉ាងច្បាស់" ថា អតីតប្រធានៗពន្ធនាគារ គឺមិនត្រូវបាន ចាត់ទុកថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះឡើយ)..." ។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី២៣:</u> "នេះគឺជាការបង្ហាញយ៉ាងច្បាស់ថា តាមច្បាប់ អវតក ប្រធាន១ពន្ធនាគារនាពេលនោះមិនសក្តិសមនឹងចាត់ទុកថា ស្ថិតនៅក្នុងប្រភេទអ្នកទទួលខុសត្រូវខ្ពស់បំផុតឡើយ" ។

ជ. <u>ចម្លើយតបរបស់ កសព, លេខយោងជើង ទំព័រទី១៥:</u> "*សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខ... កថាខណ្ឌទី៦៩ (ដែលពោលអះអាងថា *អង្គជំនុំជម្រះសាលាដំបូង បានប្រើប្រាស់សច្ចធារណ៍ហួសហេតុ* ដោយពោលថា យល់ស្របតាមសហព្រះរាជអាជ្ញា" (សង្កត់ន័យបន្ថែមដោយអក្សរទ្រេត) ។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៦៩:</u> "ហេតុនេះ គឺអង្គជំនុំជម្រះបានពឹងផ្អែកលើហួសហេតុលើសច្ចធារណ៍ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ដោយយល់ស្របតាមភស្តុតាងរបស់អយ្យការ..." ។

ឈ. <u>ចម្លើយតបរបស់ កសព, លេខយោងជើងទំព័រទី១៥:</u> "*សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខ... កថាខណ្ឌទី២៥ (ដែលនិយាយថា *អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របដោយមិនត្រឹមត្រូវ ជាមួយនឹងការសំអាងលេសដែលគ្មានមូលដ្ឋានគតិយុត្តិសមហេតុសមផល* និងដែលផ្អែកលើមូលដ្ឋាននេះសហព្រះរាជអាជ្ញា ដាក់បន្ទុកលើជនជាប់ចោទ [...] ការលើកសំអាងបែបនេះពុំមានតក្កភាព (ឡូហ្សិក) ក្នុងវិស័យច្បាប់សម្រាប់លើកមកបង្ហាញពីការធ្វើអត្តសញ្ញាណកម្មជនណាម្នាក់ថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតបានឡើយ"...) (សង្កត់ន័យបន្ថែមដោយអក្សរទ្រេត) ។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី២៥:</u> "អង្គជំនុំជម្រះ បានយល់ស្របដោយភាន់ច្រឡំតាមសេចក្តីសន្និដ្ឋានដែលគ្មានមូលដ្ឋានគតិយុត្តិ ហើយដោយពឹងផ្អែកលើសេចក្តីសន្និដ្ឋាននេះសម្រេចថា កាំង ហ្គេកអ៊ាវ ត្រូវបានចាត់ទុកថានៅក្នុងប្រភេទនៃអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម...[] សេចក្តីសន្និដ្ឋានទាំងនេះ គឺមិនត្រឹមត្រូវតាមគតិយុត្តិទេ ហើយមិនអាចយកមកធ្វើជាមូលដ្ឋានដើម្បីកំណត់ថា ជនណាម្នាក់ស្ថិតនៅក្នុងប្រភេទអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតបានឡើយ" ។

ញ. <u>ចម្លើយតបរបស់ កសព, លេខយោងជើងទំព័រទី១៦:</u> "*សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខ... កថាខណ្ឌទី៩១, ៩៩ (ដែលបកស្រាយដោយខុសថា ប្រការដែលមានចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងមួយរូបបានមានមតិជំទាស់អំពីការកំណត់

ទោសរួម (បរិមាណនៃការផ្តន្ទាទោស) ដោយមានន័យថាមាន "ភាពមិនប្រក្រតីនៅក្នុងការផ្តល់យុត្តិធម៌ដល់ជនជាប់ចោទ" ទៅវិញ...)"។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៨៩:</u> "អង្គជំនុំជម្រះសាលាដំបូង រកសម្តេងគាំទ្រជាឯកច្ឆ័ន្ទមិនបានគ្រប់ទេ ។ នេះគឺជាការបង្ហាញឱ្យឃើញថា សវនាការជំនុំជម្រះក្តី កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ត្រូវបានធ្វើឱ្យបាត់បង់សុពលភាព ដោយសារតែមានភាពមិនប្រក្រតី" ។

ង. <u>ចម្លើយតបរបស់ កសព, កថាខណ្ឌទី១២:</u> "បណ្តឹងសាទុក្ខរបស់មេធាវីការពារជនជាប់ចោទតវ៉ាចំពោះការសម្រេចនេះដោយចោទថាអង្គជំនុំជម្រះសាលាដំបូង"បានអនុវត្តវិធាន៨៩ដោយខុសពេលវេលា និងខុសឆ្គងនីតិវិធី"។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៧១:</u> "[អង្គជំនុំជម្រះសាលាដំបូង]បានយកវិធាន ៨៩ មកអនុវត្តដោយខុស ។ នេះគឺជាការនាំឱ្យមានវិការៈផ្នែកនីតិវិធី"។

ច. <u>ចម្លើយតបរបស់ កសព, លេខយោងជើងទំព័រទី៤២:</u> "*សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខ...កថាខណ្ឌទី៣៣ ("ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ទេ គាត់មានឋានានុក្រមទាប=> គាត់គ្មានសិទ្ធិបញ្ជា និងគ្មានសិទ្ធិសម្រេច => មានការទទួលខុសត្រូវទាប")"។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៣៣ (សង្កត់ន័យបន្ថែមដោយអក្សរទ្រេត):</u> "កាំង ហ្កេកអ៊ាវ មិនមែនជាមេដឹកនាំជាន់ខ្ពស់ទេ ហើយមានមុខតំណែងទាបនៅក្នុងឋានានុក្រម => គាត់គ្មានអំណាចក្នុងការចេញបញ្ជា ឬធ្វើសេចក្តីសម្រេច=> គាត់មានការទទួលខុសត្រូវដែលមានការកំរិត"។

ឆ. <u>ចម្លើយតបរបស់ កសព, លេខយោងជើងទំព័រទី៤២:</u> "*សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខ...កថាខណ្ឌទី២២ (ដែលថ្លែងថា "ឌុច" មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អវតកទេ ពីព្រោះ "គាត់មិនស្ថិតនៅក្នុងជំពូកមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរចនាសម្ព័ន្ធមេដឹកនាំនៃមេដឹកនាំជាន់ខ្ពស់" ក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ)"។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី២២:</u> "... គាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏មិនមែននៅស្ថិតនៅក្នុងប្រភេទអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្រោមរបបនេះដែរ" ។

ឈ. **<u>ចម្លើយតបរបស់ កសព, លេខយោងជើងទំព័រទី៤៣:</u>** "*សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខ...កថាខណ្ឌទី៣៣ ("ដែលតវ៉ាថា ឌុច មិនអាចចាត់ទុកថាជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតបានទេ ដោយសារថា "ការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ គឺផ្អែកទៅលើអំណាចឋានានុក្រមដែលត្រូវបានកំណត់ដោយច្បាប់របស់បុគ្គលនោះ" ហើយ ឌុច មានឋានានុក្រម "នៅថ្នាក់ក្រោម")"។

**<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៣៣:</u>** "... ការទទួលខុសត្រូវរបស់បុគ្គលណាម្នាក់ គឺអាស្រ័យទៅលើសិទ្ធិអំណាចតាមផ្លូវច្បាប់នៅក្នុងឋានានុក្រម... [ឌុច] មានឋានៈទាបទេនៅក្នុងឋានានុក្រមនេះ..."។

ញ. **<u>ចម្លើយតបរបស់ កសព, លេខយោងជើងទំព័រទី៤៣:</u>** "*សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខ...កថាខណ្ឌទី៣៧, ៣៨ ("ដែលនិយាយថា ច្បាប់ អវតក "មិនអនុញ្ញាតឱ្យផ្តន្ទាទោសជនដែលទទួលខុសត្រូវថ្នាក់ទាប ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ព្រោះដោយយល់ថា ជនទាំងនេះអនុវត្តតាមបញ្ជារបស់ថ្នាក់លើ")..."។

**<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៣៧:</u>** "[] ច្បាប់ អវតក ដែលផ្អែកលើមូលដ្ឋានក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺមិនបានចែងពីការផ្តន្ទាទោសអ្នកទាំងឡាយដែលកាន់មុខតំណែងទាបនៅក្នុងឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យ និង បកក ចំពោះឧក្រិដ្ឋកម្ម ដែលពួកគេប្រហែលជាបានប្រព្រឹត្តមែននៅក្នុងអម្លុងពេលនោះ បើសិនជាជនទាំងនោះអនុវត្តតាមបញ្ជាពីថ្នាក់លើរបស់ពួកគេ"។

ដ. **<u>ចម្លើយតបរបស់ កសព, លេខយោងជើងទំព័រទី៤៣:</u>** "*សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខ...កថាខណ្ឌទី១០០ ("សាលាជម្រះក្តី អវតក មិនមានយុត្តាធិការលើ កាំង ហ្កេកអ៊ាវ *ហៅ* [ឌុច] ទេ...ព្រោះថា ឋានៈរបស់ ឌុច ទាំងនៅក្នុងជួររដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជា គឺជាឋានៈថ្នាក់មូលដ្ឋានជាន់ទាបមិនមែនជាឋានៈជាន់ខ្ពស់ទេ")។

**<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី១០០:</u>** "[] អង្គជំនុំជម្រះមិនមានយុត្តាធិការទៅលើ ឌុច ទេ ។ ភស្តុតាងបានបង្ហាញថា គាត់កាន់កាប់មុខតំណែងជាន់ទាប ហើយមិនមែនជាមុខដំណែងជាន់ខ្ពស់នោះទេ ទាំងនៅក្នុងជួររដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជានៅក្នុងជួរបក្សមកុម្មុយនីស្តកម្ពុជា"។

ថ. <u>ចម្លើយតបរបស់ កសព, លេខយោងជើងទំព័រទី៤៣:</u> "*សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខ... កថាខណ្ឌទី៦៥ (ដែលអះអាងថា ច្បាប់ អវតក "មិនគ្របដណ្តប់លើក្រុមជនដែលអនុវត្តតាមបញ្ជាឱ្យប្រព្រឹត្តបទឧក្រិដ្ឋនោះទេ និងដែលមិនមានអំណាចធ្វើសេចក្តីសម្រេចចិត្តដោយនយោបាយផ្ទាល់ខ្លួន" ប៉ុន្តែផ្ទុយទៅវិញគឺ "គ្របដណ្តប់តែទៅលើក្រុមបុគ្គលទាំងឡាយដែលមានសិទ្ធិសម្រេចចិត្តនយោបាយផ្ទាល់ខ្លួន ដែលបង្កើតបានជាគោលនយោបាយ និងបង្កើតបានជាបទឧក្រិដ្ឋប៉ុណ្ណោះ")។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៦៥:</u> "ច្បាប់ អវតក មិនអនុវត្តចំពោះជនទាំងឡាយដែលអនុវត្តតាមបញ្ជាឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ហើយដែលមិនមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចបែបនេះនោះទេ" ។ "គឺបានន័យថា អនុវត្តចំពោះតែជនទាំងឡាយណាដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចខាងនយោបាយ, ខាងការបង្កើតគោលនយោបាយឧក្រិដ្ឋនានា និងដែលធ្វើឱ្យប្រាកដថាគោលនយោបាយទាំងនោះត្រូវបានអនុវត្ត" តែប៉ុណ្ណោះ។

ទ. <u>ចម្លើយតបរបស់ កសព, លេខយោងជើងទំព័រទី៥៥:</u> "*សូមអាន* សារណាបណ្តឹងសាទុក្ខ... កថាខណ្ឌទី២៥ (ដែលថ្លែងថា *អង្គជំនុំជម្រះ បានយល់ស្របដោយមិនត្រឹមត្រូវជាមួយនឹងការសំអាងលេសដែលគ្មានមូលដ្ឋានគតិយុត្តិសមហេតុសមផល* [នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ] ហើយដែលអយ្យការបានពឹងផ្អែកក្នុងការដាក់បន្ទុកលើជនជាប់ចោទដោយចោទប្រកាន់ថា ជនជាប់ចោទស្ថិតក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតដោយសំអាងថា មន្ទីរសន្តិសុខស-២១ គឺជាមន្ទីរសន្តិសុខដ៏សំខាន់ដែលធ្វើប្រតិបត្តិការពាសពេញប្រទេស។*ការសំអាងបែបនេះ ពុំមានលក្ខណៈតក្កៈក្នុងវិស័យច្បាប់* សម្រាប់លើកមកបង្ហាញអំពីការធ្វើអត្តសញ្ញាណកម្មនៃអ្នកទទួលខុសត្រូវនោះទេ" (សង្កត់ន័យបន្ថែមដោយអក្សរទ្រេត) ..."។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី២៥:</u> "*អង្គជំនុំជម្រះមានការភាន់ច្រឡំដោយបានយល់ស្របតាមសេចក្តីសន្និដ្ឋានដែលថា*គ្មានមូលដ្ឋានគតិយុត្តិ និងដោយបានពឹងផ្អែកលើសេចក្តីសន្និដ្ឋាននេះក្នុងការសម្រេចឱ្យ កាំង ហ្គេកអ៊ាវ ត្រូវបានចាត់ទុកនៅក្នុងប្រភេទអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ពីព្រោះមន្ទីរសន្តិសុខស-២១ គឺជាមន្ទីរសន្តិសុខសំខាន់ណាស់ដែលធ្វើប្រតិបត្តិការនៅក្នុងទូទាំងប្រទេស ។ ការសំអាងនេះគឺមិនត្រឹមត្រូវតាមគតិយុត្តិទេ ហើយមិនអាចយកមកធ្វើជាមូលដ្ឋានដើម្បីកំណត់ថា ជនណាម្នាក់ស្ថិតនៅក្នុងប្រភេទអ្នកទទួលខុសត្រូវខ្ពស់បំផុតបានឡើយ" ។

ន. <u>ចម្លើយតបរបស់ កសព, លេខយោងជើងទំព័រទី៥៥:</u> "*សូមអាន* សារណាបណ្តឹងសាទុក្ខ... កថាខណ្ឌទី២៥ (ដែលលើកសំអាងដោយងងិតងងល់លើ "ទ្រឹស្តីច្បាប់មិនច្បាស់លាស់ក្នុងការ

កំណត់និយមន័យអំពីអ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែលបានពោលអះអាងថាមិនរាប់បញ្ចូលនូវជនទាំងឡាយណាដែលទទួលបញ្ជាពីថ្នាក់លើទេ)"។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី២៥:</u> "តាមទស្សនៈវិស័យខាងច្បាប់នៅក្នុងការកំណត់ថា តើបុគ្គលណាម្នាក់សក្តិសមនឹងចាត់ទុក ឬមិនចាត់ទុកជាប្រភេទជនដែលទទួលខុសត្រូវខ្ពស់បំផុតនោះ ចាំបាច់គេត្រូវតែធ្វើការកំណត់អំពីសិទ្ធិអំណាចដែលជននោះបានកាន់កាប់ ដោយផ្អែកទៅលើតួនាទីរបស់ជននោះ។

ប. <u>ចម្លើយតបរបស់ កសព, កថាខណ្ឌទី៣៧:</u> "ដើមបណ្តឹងសាទុក្ខបានធ្វើការកត់សំគាល់ដោយខ្លួនឯងថានៅពេលវាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ អង្គចៅក្រមបញ្ជូនសំណុំរឿងរបស់តុលាការ ICTY បានផ្អែកលើ "លើចំនួនជនរងគ្រោះ, ដែនកំណត់ភូមិសាស្ត្រ, និងពេលវេលា, របៀបដែលត្រូវបានចោទថាបានប្រព្រឹត្ត ព្រមទាំងចំនួននៃអង្គហេតុនីមួយៗដែលបានកើតមានឡើង"។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី១៩:</u> "...កត្តាផ្សេងៗដូចជា ចំនួនជនរងគ្រោះ, ដែនកំណត់នៃភូមិសាស្ត្រ និងពេលវេលានៃឧក្រិដ្ឋកម្ម, ហើយនឹងរបៀបដែលត្រូវបានចោទថាពួកគេបានប្រព្រឹត្ត ព្រមទាំងចំនួននៃព្រឹត្តហេតុនានាដែលបានកើតឡើងដាច់ដោយឡែកៗពីគ្នានៃឧក្រិដ្ឋកម្ម..."។

ផ. <u>ចម្លើយតបរបស់ កសព, កថាខណ្ឌទី៤៨:</u> "ជាទឡ្ហីករណ៍ទីពីរនៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី សហមេធាវីបានលើកឡើងចោទថា "មានការភាន់ច្រឡំនៅក្នុងការផ្តន្ទាទោស"។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, ទំព័រ១៩(ចំណងជើង):</u> "... ការភាន់ច្រឡំទាក់ទងនឹងការសម្រេចទោស និងការផ្តន្ទាទោស"។

ព. <u>ចម្លើយតបរបស់ កសព, កថាខណ្ឌទី៤៨:</u> "ដោយឡែក សហមេធាវីការពារក្តីបានលើកឡើងចោទថា អង្គជំនុំជម្រះសាលាដំបូង "ខកខានមិនបានពិនិត្យមើលវិធាន៨៧នៃវិធានផ្ទៃក្នុងរបស់ អវតក និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីជនជាប់ចោទ...ដែលនាំឱ្យភស្តុតាងដោះបន្ទុកមិនត្រូវបានពិនិត្យទាំងស្រុងក្នុងការធ្វើឱ្យប្រាកដថា អវតក ពិតជាគ្មានយុត្តាធិការលើបុគ្គលជនជាប់ចោទតាមការសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ"។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៦៦:</u> "ដោយច្រានចោលនូវសេចក្តីសន្និដ្ឋានដូច ដែលមាននៅក្នុងសេចក្តីសន្និដ្ឋានស្ថាពររបស់មេធាវីការពារក្តី អង្គជំនុំជម្រះសាលាដំបូងបាន យកចិត្តទុកដាក់ពិនិត្យតែទៅលើវិធាន៨៩នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ តែមិនបានពិនិត្យលើវិធាន ៨៧នោះឡើយ ។ ការច្រានចោលនេះ គឺដោយផ្អែកលើភស្តុតាងដែលបានដាក់បង្ហាញនៅ ចំពោះមុខអង្គជំនុំជម្រះ និងលើវិធាន៨៩តែប៉ុណ្ណោះ ដែលជាការរំលោភលើវិធាន៨៧នៃ វិធានផ្ទៃក្នុង ដោយសារថា ភស្តុតាងដោះបន្ទុកមិនត្រូវបានធ្វើការពិនិត្យវាយតម្លៃដើម្បីផ្ទៀង ផ្ទាត់ថា តើដូចសេចក្តីសន្និដ្ឋានស្ថាពររបស់មេធាវីការពារជនជាប់ចោទដែលថា អវតក ពិតជា គ្មានយុត្តាធិការលើ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច មែនដែរ ឬទេ?"។

ភ. <u>ចម្លើយតបរបស់ កសព, កថាខណ្ឌទី៤៨:</u> "ជាងនេះទៅទៀត បានចោទប្រកាន់ថា "អង្គជំនុំ ជម្រះបានប្រើប្រាស់សច្ចធារណ៍ហួសហេតុ ដោយពោលថា យល់ស្របតាមសហព្រះរាជ អាជ្ញា ហើយមិនបានលើកសំអាងហេតុណាមួយមកធ្វើជាអំណះអំណាងដែលគួរឱ្យជឿបាន ដោយគ្មានវិមតិសង្ស័យលើរាល់ភស្តុតាងដែលខ្លួនបានប្រើប្រាស់ ធ្វើជាសំអាងហេតុក្នុងការ កំណត់អំពីយុត្តាធិការបុគ្គលរបស់ខ្លួនលើជនជាប់ចោទនោះទេ"។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៦៩:</u> "ហេតុនេះ គឺអង្គជំនុំជម្រះបានប្រើប្រាស់ សច្ចធារណ៍ហួសហេតុប្រឆាំងនឹង កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ដោយយល់ស្របតាមភស្តុតាង របស់អយ្យការ និងដោយមិនបានលើកឡើងអំពីហេតុផលដែលមានសុពលភាពណាមួយថាតើ ហេតុអ្វីបានជា អង្គជំនុំជម្រះជឿជាក់ដោយហួសពីវិមតិសង្ស័យលើភស្តុតាងដែលអនុញ្ញាតឱ្យ អង្គជំនុំជម្រះ សម្រេចថា ខ្លួនពិតជាមានយុត្តាធិការបុគ្គល"។

ម. <u>ចម្លើយតបរបស់ កសព, លេខយោងជើងទំព័រទី១១៥:</u> "*សូមអាន ឧទាហរណ៍ដូចជា* សារណា បណ្តឹងសាទុក្ខ...កថាខណ្ឌទី៦៦ (ដោយបានលើកឡើងថា "ភស្តុតាងដោះបន្ទុកមិន[ត្រូវបាន] ពិនិត្យទាំងស្រុង ដើម្បីឱ្យប្រាកដថា អវតក គ្មានយុត្តាធិការលើជនជាប់ចោទនោះទេ")..."។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៦៦:</u> "... គ្មានភស្តុតាងដោះបន្ទុកណាត្រូវបាន យកមកពិនិត្យវាយតម្លៃដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ថា តើដូចសេចក្តីសន្និដ្ឋានស្ថាពររបស់ មេធាវីការពារជនជាប់ចោទដែលថា ជាក់ស្តែង អវតក ពិតជាគ្មានយុត្តាធិការលើ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច មែន ឬក៏អត់? នោះឡើយ"។

យ. <u>ចម្លើយតបរបស់ កសព, លេខយោងជើងទំព័រទី១១៥:</u> "*សូមអាន ឧទាហរណ៍ដូចជា* សារណា បណ្តឹងសាទុក្ខ...កថាខណ្ឌទី៦៩ (ដែលបានលើកឡើងចោទថា អង្គជំនុំជម្រះសាលាដំបូង៖

"បានខកខានមិនបានពិនិត្យមើលភស្តុតាងដោះបន្ទុកលើយុត្តាធិការបុគ្គលទាំងស្រុង ដែលលើកឡើងដោយមេធាវីជនការពារក្តី")...។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៦៩:</u> "[អង្គជំនុំជម្រះសាលាដំបូង]... [បាន]ភ្លេចមិនបានពិនិត្យមើលលើភស្តុតាងដោះបន្ទុក អំពីលក្ខខណ្ឌតម្រូវសម្រាប់ការអនុវត្តយុត្តាធិការបុគ្គលឡើយ"។

វ. <u>ចម្លើយតបរបស់ កសព, លេខយោងជើងទំព័រទី១១៥:</u> "*សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខ...កថាខណ្ឌទី៧០ (ដែលបានលើកឡើងថា "បើសិនជា "ខ្លួនបានពិនិត្យមើលភស្តុតាងតាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ"អង្គជំនុំជម្រះមុខជានឹងយល់ស្របថា ពិតជាគ្មានយុត្តាធិការលើបុគ្គលជនជាប់ចោទប្រាកដមែន"។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៧០:</u> "...អង្គជំនុំជម្រះសាលាដំបូង-បើសិនជាបានពិនិត្យមើលភស្តុតាងដែលបានដាក់ជូនដោយមេធាវី ដូចដែលមាននៅក្នុងសេចក្តីសន្និដ្ឋានស្តាពររបស់មេធាវីនោះ - មុខជានឹងទទួលស្គាល់ថា ខ្លួនពិតជាគ្មានយុត្តាធិការលើ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ប្រាកដមែន"។

ល. <u>ចម្លើយតបរបស់ កសព, កថាខណ្ឌទី៥៦:</u> ("...អង្គជំនុំជម្រះសាលាដំបូងបានដឹង ហើយបានយកចិត្តទុកដាក់អំពីប្រភេទនៃអង្គហេតុ និងភស្តុតាងនានាដែលដើមបណ្តឹងឧទ្ធរណ៍បានកំណត់ថាជាប្រភេទ "ដែលមិនទាន់ត្រូវបានបង្ហាញជូនដោយអង្គជំនុំជម្រះសាលាដំបូងនៅឡើយ")។

<u>បណ្តឹងសាទុក្ខដែលបានកែតម្រូវ, កថាខណ្ឌទី៧២ (ចំណងជើង):</u> "ភស្តុតាងដោះបន្ទុកដែលមិនទាន់បានពិនិត្យដោយអង្គជំនុំជម្រះ"។

## ៤. សេចក្តីសន្និដ្ឋាន

១០. សហព្រះរាជអាជ្ញា សូមគាំទ្រចំពោះការអនុវត្តក្នុងការដាក់ជូននូវឯកសារបកប្រែត្រឹមត្រូវដែលបានដាក់ទាន់ពេលវេលាដើម្បីប្រសិទ្ធិភាពរបស់តុលាការ ប្រយោជន៍នឹងផ្តល់ដល់ភាគីនានានូវឱកាសគ្រប់គ្រាន់ដើម្បីធ្វើការឆ្លើយតបឲ្យបានត្រឹមត្រូវទៅនឹងសារណានានា។

១១. សហព្រះរាជអាជ្ញា សូមគូសបញ្ជាក់ថា មានភាពខុសគ្នាដោយអន្លើ ដែលបណ្តាលមកពីបណ្តឹងសាទុក្ខដែលបានកែតម្រូវ ដើម្បីជាប្រយោជន៍ដល់អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងការធ្វើការវាយតម្លៃទៅលើបណ្តឹងសាទុក្ខដែលបានដាក់ជូនដោយមេធាវីការពារក្តី និងដាក់ជូនដោយសហព្រះរាជអាជ្ញា៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី16 ខែមីនា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |